# បញ្ជីមន្ត្រីជំនួយការក្រុមគាំទ្រនៃក្រុមការងារគណនេយ្យភាពខេត្ត ក្រុង ដែលត្រូវជ្រើសរើស

| ល.រ | ខេត្ត ក្រុង | ស្រុក-ខណ្ឌ | ឃុំ សង្កាត់ | ចំនួនមន្ត្រី |
|---|---|---|---|---|
| 1 | បន្ទាយមានជ័យ | 8 | 64 | 2 នាក់ |
| 2 | បាត់ដំបង | 13 | 96 | 2 នាក់ |
| 3 | កំពង់ចាម | 16 | 173 | 3 នាក់ |
| 4 | កំពង់ឆ្នាំង | 8 | 69 | 2 នាក់ |
| 5 | កំពង់ស្ពឺ | 8 | 87 | 2 នាក់ |
| 6 | កំពង់ធំ | 8 | 81 | 2 នាក់ |
| 7 | កំពត | 8 | 92 | 2 នាក់ |
| 8 | កណ្តាល | 11 | 147 | 3 នាក់ |
| 9 | កោះកុង | 8 | 33 | 1 នាក់ |
| 10 | ក្រចេះ | 5 | 46 | 1 នាក់ |
| 11 | មណ្ឌលគិរី | 5 | 21 | 1 នាក់ |
| 12 | រាជធានីភ្នំពេញ | 7 | 76 | 2 នាក់ |
| 13 | ព្រះវិហារ | 7 | 49 | 1 នាក់ |
| 14 | ព្រៃវែង | 12 | 116 | 3 នាក់ |
| 15 | ពោធិ៍សាត់ | 6 | 49 | 1 នាក់ |
| 16 | រតនគិរី | 9 | 49 | 1 នាក់ |
| 17 | សៀមរាប | 12 | 100 | 3 នាក់ |
| 18 | ក្រុងព្រះសីហនុ | 3 | 22 | 1 នាក់ |
| 19 | ស្ទឹងត្រែង | 5 | 34 | 1 នាក់ |
| 20 | ស្វាយរៀង | 7 | 80 | 2 នាក់ |
| 21 | តាកែវ | 10 | 100 | 3 នាក់ |
| 22 | ឧត្តរមានជ័យ | 2 | 24 | 1 នាក់ |
| 23 | ក្រុងកែប | 2 | 5 | 1 នាក់ |
| 24 | ក្រុងប៉ៃលិន | 5 | 8 | 1 នាក់ |
| | **សរុប** | **185** | **1621** | **42** នាក់ |

# លក្ខខណ្ឌការងារ
# សម្រាប់មន្ត្រីជំនួយការក្រុមគាំទ្រនៃក្រុមការងារគណនេយ្យភាពខេត្ត ក្រុង

- តួនាទី : មន្ត្រីជំនួយការក្រុមគាំទ្រនៃក្រុមការងារគណនេយ្យភាពខេត្ត ក្រុង
- ឈ្មោះគម្រោង : គម្រោងគាំទ្រការអភិវឌ្ឍន៍បែបប្រជាធិបតេយ្យតាមរយៈវិមជ្ឈការ និង វិសហមជ្ឈការ (PSDD)
- ទីកន្លែង : លេខាធិការដ្ឋានរបស់គ.ប្រ/គ.អ.ជ.ខ
- រយៈពេល : ០១ ឆ្នាំ (ធ្វើការវាយតម្លៃនៅរៀងរាល់ចុងឆ្នាំ)

## ១. សាវតា

ក្រុមការងារគណនេយ្យភាពខេត្ត ក្រុងត្រូវបានបង្កើតឡើងចាប់តាំងពីចុងឆ្នាំ២០០៥។ នៅឆ្នាំ២០០៨ គណៈកម្មាធិការជាតិដឹកនាំការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការបានដាក់ចេញនូវសេចក្តីណែនាំថ្មីស្តីពីការរៀបចំកែសម្រួល និងការបង្កើតក្រុមការងារគណនេយ្យភាពខេត្ត ក្រុង។ ការបង្កើតក្រុមការងារគណនេយ្យភាពខេត្ត ក្រុងមានគោលបំណង ដើម្បីធានានូវគណនេយ្យភាព តម្លាភាព និងប្រសិទ្ធិភាពក្នុងការប្រើប្រាស់ថវិកាគ្រប់ប្រភពទាំងអស់ដែលស្ថិតក្រោមផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំរបស់គណៈកម្មាធិការជាតិដឹកនាំការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ និងមូលនិធិឃុំ សង្កាត់ និងរួមចំណែកក្នុងការពង្រឹងការអនុវត្តការងាររបស់ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ស្របតាមគោលការណ៍ច្បាប់។ ក្រុមការងារគណនេយ្យភាពខេត្ត ក្រុង ត្រូវបង្កើតក្រុមគាំទ្រ ដើម្បីជួយការអនុវត្តកិច្ចការប្រចាំថ្ងៃរបស់ខ្លួន។ ក្រុមគាំទ្រនៃក្រុមការងារគណនេយ្យភាពខេត្ត ក្រុងដឹកនាំដោយលេខាធិការរបស់ក្រុមការងារគណនេយ្យភាពខេត្ត ក្រុង និងមានមន្ត្រីជំនួយការចំនួន ១-៣ នាក់បន្ថែមទៀតដែលត្រូវជ្រើសរើសឡើងតាមការប្រកួតប្រជែង។

## ២. ភារកិច្ចរបស់មន្ត្រីជំនួយការ

មន្ត្រីជំនួយការ ១-៣ រូបនេះ ត្រូវជួយការងារប្រចាំថ្ងៃរបស់ក្រុមគាំទ្រនៃក្រុមការងារគណនេយ្យភាពខេត្ត ក្រុង ដោយត្រូវបំពេញភារកិច្ចដូចខាងក្រោម:

- ជួយក្នុងការរៀបចំផែនការសកម្មភាព និងគម្រោងថវិកាប្រចាំឆ្នាំក្នុងការអនុវត្តតួនាទី និងភារកិច្ចរបស់ក្រុមការងារគណនេយ្យភាពខេត្ត ក្រុង ដើម្បីដាក់បញ្ចូលក្នុងផែនការ និងថវិការបស់គ.ប្រនៃ គ.អ.ជ.ខ
- ជួយរៀបចំផែនការ និងចូលរួមក្នុងការចុះស្រាវជ្រាវពាក្យបណ្តឹង ដែលពាក់ព័ន្ធភាពមិនប្រក្រតីនៃការប្រើប្រាស់ថវិកា ដែលអង្គប្រជុំបានសម្រេចស៊ើបអង្កេតលើករណីទាំងនោះ

- រៀបចំរបាយការណ៍ពាក្យបណ្តឹងលើករណីនីមួយៗ ដែលក្រុមស្រាវជ្រាវបានចុះស៊ើបអង្កេត និងដាក់ជូនលេខាធិការពិនិត្យមុននឹងរាយការណ៍ជូនអង្គប្រជុំក្រុមការងារគណនេយ្យភាពខេត្ត ក្រុង
- រៀបចំរបាយការណ៍រីកចម្រើនជាប្រចាំ ស្របតាមទម្រង់ដែលបានកំណត់ និងដាក់ជូនលេខាធិការរបស់ក្រុមការងារគណនេយ្យភាពខេត្ត ក្រុងដើម្បីពិនិត្យ និងកែសម្រួលនិងផ្ញើរបាយការណ៍រីកចម្រើនចុងក្រោយមកក្រុមក្រុមការងារគណនេយ្យភាពជាតិ
- ធ្វើការកត់ត្រាព័ត៌មានពាក្យបណ្តឹងដែលបានប្រមូល សេចក្តីសម្រេចរបស់អង្គប្រជុំ និងដំណោះស្រាយដែលបានអនុវត្តតាមកាលបរិច្ឆេទនីមួយៗស្របតាមទម្រង់ដែលបានកំណត់
- ជួយលេខាធិការក្នុងការរៀបចំអង្គប្រជុំរបស់ក្រុមការងារគណនេយ្យភាពខេត្ត ក្រុង ដូចជាការរៀបចំទីកន្លែងប្រជុំ ការធ្វើលិខិតអញ្ជើញប្រជុំ ការរៀបចំកំណត់ហេតុ និងចែកចាយដល់សមាជិកអង្គប្រជុំឱ្យបានជាប្រចាំ ព្រមទាំងរៀបចំសេចក្តីព្រាងរាល់លិខិតស្នាមដែលពាក់ព័ន្ធដល់សេចក្តីសម្រេចរបស់ក្រុមការងារគណនេយ្យភាពខេត្ត ក្រុងបានឯកភាព
- រៀបចំ និងសម្របសម្រួលការចែកចាយព័ត៌មានដែលទាក់ទងនឹងក្រុមការងារគណនេយ្យភាព និងផ្សព្វផ្សាយព័ត៌មានទាំងនោះ ដល់អ្នកពាក់ព័ន្ធ ជាពិសេសក្រុមប្រឹក្សាឃុំ និងប្រជាពលរដ្ឋ។
- សហការជាមួយអ្នកសម្របសម្រួលខេត្ត ក្រុង ស្រុក ខណ្ឌ ក្នុងការប្រមូលពាក្យបណ្តឹង ការតាមដានក្នុងការបើកប្រអប់សំបុត្រ ធានាសុវត្ថិភាពប្រអប់សំបុត្រ និងធ្វើរបាយការណ៍ករណីមានការបាត់បង់
- ចូលរួម និងសម្របសម្រួលអង្គប្រជុំ សិក្ខាសាលា ឬវគ្គបណ្តុះបណ្តាលផ្សេងៗ ដែលពាក់ព័ន្ធអំពីរបៀបរបបធ្វើការងាររបស់ក្រុមការងារគណនេយ្យភាពខេត្ត ក្រុង។
- ជួយកិច្ចការផ្សេងៗទៀតដែលតម្រូវការចាំបាច់ បើមានការប្រគល់ជូនដោយលេខាធិការរបស់ក្រុមការ-ងារគណនេយ្យភាពខេត្ត ក្រុង។

## ៣. ការគ្រប់គ្រង

មន្ត្រីជាប់កិច្ចសន្យា ១-៣រូប ដែលបំរើការឱ្យក្រុមគាំទ្រ ត្រូវស្ថិតនៅក្រោមការគ្រប់គ្រងទូទៅនៃអភិបាលខេត្ត ក្រុង និងស្ថិតនៅក្រោមការគ្រប់គ្រងផ្ទាល់របស់លេខាធិការនៃក្រុមការងារគណនេយ្យភាពខេត្ត ក្រុង។ ការវាយតម្លៃនឹងត្រូវធ្វើរៀងរាល់ឆ្នាំលើការអនុវត្តការងាររបស់មន្ត្រីជាប់កិច្ចសន្យាទាំងនោះមុននឹងបន្តកិច្ចសន្យាបំរើការងារថ្មី។

## ៤. សហប្រតិបត្តិការបច្ចេកទេស

មន្ត្រីជំនួយការក្រុមគាំទ្រនៃក្រុមការងារគណនេយ្យភាពខេត្ត ក្រុង ត្រូវសហការឱ្យបានជិតស្និទ្ធិជាមួយផ្នែករបស់គ.ប្រ និងអង្គភាពរដ្ឋបាលមូលដ្ឋាន លើកិច្ចការទាំងឡាយដែលពាក់ព័ន្ធ និងត្រូវធ្វើការជាដៃគូឱ្យមានប្រសិទ្ធភាពជាមួយមន្ត្រីទីប្រឹក្សាពាក់ព័ន្ធរបស់គម្រោង PSDD និងអង្គភាពពាក់ព័ន្ធផ្សេងៗទៀត។

## ៥. លក្ខណៈសម្បត្តិ និងបទពិសោធន៍ការងារ

- មិនមែនជាមន្ត្រីរាជការ ឬជាមន្ត្រីរាជការនៃមន្ទីរ/អង្គភាពពាក់ព័ន្ធនានាក្នុងខេត្ត ក្រុង
- មានសញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ ឬសញ្ញាប័ត្រមានតម្លៃស្មើ ជាពិសេសពាក់ព័ន្ធកិច្ចការរដ្ឋបាលសាធារណៈ
- មានបទពិសោធន៍យ៉ាងតិច ០២ ឆ្នាំ ដែលមានពាក់ព័ន្ធទៅនឹងការអនុវត្តគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ ឬជំនាញដែលទាក់ទងការងារអភិវឌ្ឍនៅមូលដ្ឋាន
- មានឆន្ទៈខ្ពស់ក្នុងការស៊ើបអង្កេតលើករណីពាក្យបណ្តឹងតវ៉ា
- មានចំណង់ចំណូលចិត្តចុះធ្វើការនៅតាមមូលដ្ឋាន និងអាចស្នាក់ពេលយប់នៅតាមភូមិ ឃុំ
- បុរស ឬស្ត្រីមានអាយុយ៉ាងតិច ១៨ ឆ្នាំ
- ស្ត្រីមានអាទិភាពសម្រាប់ការជ្រើសរើសបំរើការងារនេះ។